**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ |
| ភាគីដាក់ឯកសារ | សហមេធាវីរបស់លោក នួន ជា |
| ដាក់ជូន | អង្គជំនុំជម្រះសាលាដំបូង |
| ភាសាដើម | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ | ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១៦ |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jul-2016, 11:56
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ សាធារណៈ (កោសលុប)

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន

ឈ្មោះមន្ត្រីកត់ត្រា

ហត្ថលេខា

---

**សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា តាមវិធាន ៨៧(៤) សុំឲ្យទទួលយកធ្វើជាភស្តុតាង នូវឯកសាររបស់ ROBERT LEMKIN (2-TCW-877) និងឯកសារពាក់ព័ន្ធដទៃទៀត មុនពេលផ្តល់សក្ខីកម្មរបស់សាក្សី [redacted] (2-TCW-829)**

---

**ដាក់ដោយ÷**

**ក្រុមមេធាវីការពារក្តី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
DY Socheata

**ផ្ញើជូន÷**

**សហមេធាវីរបស់ ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា÷**

ជា លាង
Nicholas KOUMJIAN

**សហមេធាវី តំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០១៦ សហមេធាវីការពារក្តីរបស់ នួន ជា ("មេធាវីការពារក្តី") បានដាក់សំណើសុំឱ្យពិចារណា និង ទទួលយកភស្តុតាងបន្ថែមទាក់ទិននឹងភស្តុតាងដែលបានផ្តល់ដល់អង្គជំនុំជម្រះតុលាការកំពូលដោយ Robert Lemkin និងអត្ថបទដែលពាក់ព័ន្ធដែលបានបោះពុម្ពផ្សាយដោយ Cambodia Daily Weekend នៅថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០១៦ "សំណើសុំភស្តុតាង Lemkin")[1]។ នៅថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានដាក់ចម្លើយតបរបស់ខ្លួនដែលបញ្ចូលនូវសំណើថ្មីមួយសុំឱ្យស៊ើបអង្កេត ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី")[2]។ នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ មេធាវីការពារក្តីបានស្នើដាក់សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី។ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានបដិសេធសំណើរបស់មេធាវីការពារក្តីក្នុងការឆ្លើយតប ក៏ប៉ុន្តែផ្តល់សិទ្ធិក្នុងការធ្វើសារណាឆ្លើយតប[3]។ ដោយអនុលោមតាមមាត្រា ៨.៤ នៃការណែនាំអំពីការដាក់ឯកសារនៅចំពោះមុខ អវតក និងអនុលោមតាមការបង្គាប់របស់អង្គជំនុំជម្រះទាក់ទងនឹងចម្លើយតប សារណាឆ្លើយតប និងការដាក់ឯកសារតែមួយភាសាក្នុងករណីពិសេស[4] មេធាវីការពារក្តីសូមដាក់សារណាឆ្លើយតបនេះទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី ("សារណាឆ្លើយតប")។

## II. អំណះអំណាង

2. ដូចដែលខ្លួនបានឆ្លើយតបនៅក្នុងចម្លើយតបរបស់ខ្លួននៅចំពោះមុខតុលាការកំពូល[5] សហព្រះរាជអាជ្ញា

---

[1] **E416** "សំណើរបស់ នួន ជា តាមវិធាន ៨៧(៤) សុំឱ្យទទួលយកធ្វើជាភស្តុតាង នូវឯកសាររបស់ ROBERT LEMKIN (2-TCW-877) និងឯកសារពាក់ព័ន្ធដទៃទៀត មុនពេលផ្តល់សក្ខីកម្មរបស់សាក្សី [redacted] (2-TCW-829)"។

[2] **E416/1** "សហព្រះរាជអាជ្ញា៖ ១) ចម្លើយតបទៅនឹងសំណើរបស់ នួន ជា តាមវិធាន ៨៧(៤) សុំឱ្យទទួលយកធ្វើជាភស្តុតាង នូវឯកសាររបស់ ROBERT LEMKIN (2-TCW-877) និងអត្ថបទ ដីខេមបូឌា ដេលី និង ២) សំណើសុំបំពេញកិច្ចស៊ើបសួរដែលពាក់ព័ន្ធ អនុលោមតាមវិធាន ៩៣ នៃវិធានផ្ទៃក្នុង" ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ("ចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី")។

[3] សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ជូនទីប្រឹក្សាច្បាប់របស់មេធាវីការពារក្តី ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ (**ឯកសារភ្ជាប់ ១**)។

[4] **E64** "សេចក្តីណែនាំរបស់អង្គជំនុំជម្រះទាក់ទងនឹងសារណាតប ការឆ្លើយតបទៅនឹងសារណាតប និងការដាក់ឯកសារតែមួយភាសានៅក្នុងករណីពិសេស" ថ្ងៃទី១០ ខែ មីនា ឆ្នាំ ២០១១។

[5] **F2/4/3/3/3** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងដម្លើយតបរបស់នួន ជា ទៅនឹងសំណួរនានាស្តីពីកិច្ចស៊ើបសួរបន្ថែមរបស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងឈុតវីដេអូដែលជាកម្មសិទ្ធិរបស់ផលិតករភាពយន្ត Lemkin និង ថេត សម្បត្តិ" ថ្ងៃទី ២៣ កក្កដា ២០១៦។

ជាថ្មីម្តងទៀតបានជ្រើសរើសក្នុងការផ្តោតយកចិត្តដាក់ទៅលើយុទ្ធនាការប្រឆាំងនឹង Robert Lemkin តាមរយៈការបង្ហាញការវាយប្រហារទៅលើសមត្ថភាពវិជ្ជាជីវៈ និង ភាពស្មោះត្រង់ខាងចំណេះដឹង ជាជាងការលើកឡើងអំពីទឡ្ហីករណ៍ជាសារធាតុ។ ជាងនេះទៅទៀតនោះ ចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសំណើថ្មីរបស់ខ្លួនហាក់ដូចជាមិនសមហេតុផលសោះ។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញាមិនបដិសេធទៅនឹងការទទួលយកឯកសារជាភស្តុតាង អាស្រ័យហេតុនេះហើយត្រូវបានសន្មត់ថាឯកសារអាចជឿជាក់បាន និង ពាក់ព័ន្ធតាម*ការពិនិត្យជាបឋម*[6]។ ពិសេសជាងនេះទៅទៀតនោះ នៅក្នុងសំណើថ្មីរបស់សហព្រះរាជអាជ្ញា ខ្លួនបានសុំនូវភស្តុតាងថ្មីបន្ថែមទៀតពី Robert Lemkin។

3. ចម្លើយតបរបស់សហព្រះរាជអាជ្ញា និងសំណើថ្មី គឺជាឧទាហរណ៍មួយបន្ថែមទៀតនៃបទដ្ឋានពីរដែលអនុវត្តសម្រាប់សំណើសុំភស្តុតាងរបស់មេធាវីការពារក្តី។ ជាការពិតណាស់នៅក្នុងពេលដែលចំណាយយ៉ាងច្រើននៅក្នុងចម្លើយតបរបស់ខ្លួនទៅនឹងការខិតខំប្រឹងប្រែងបន្ថយតម្លៃ Robert Lemkin សហព្រះរាជអាជ្ញាបែរជាមិនបានលើកឡើងថា ខ្លួនបានស្នើសុំប្រើប្រាស់យ៉ាងច្រើនអំពីខ្សែភាពយន្តដែល Robert Lemkin និង ថេត សម្បត្តិ បានផលិត ហើយបានយោងជាដដែលនៅក្នុងសវនការ[7] ដែលបានដាក់ជូនអង្គជំនុំជម្រះតុលាការកំពូលនៅក្នុងខែ កញ្ញា ឆ្នាំ ២០១៤ ថា "ជំនាញស៊ើបអង្កេតរបស់ ថេត សម្បត្តិ មិនអាចជាបញ្ហានោះទេ"[8] និង ការប៉ុនប៉ងការពារប្រឆាំងទៅនឹងភាពផ្ទុយគ្នាយ៉ាងច្បាស់ក្រឡែតនេះ ដោយបានព្យាយាមមិនទំនងក្នុងការញែក Robert Lemkin ចេញពី ថេត សម្បត្តិ[9]។

## ក. សារណាឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា

### *(i)* ***ប្រតិចារិក***

4. សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសំណើរបស់មេធាវីការពារក្តីក្នុងការទទួលយកជាភស្តុតាងនូវប្រតិ

---

[6] **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ(E289) និងសម្លើយតបរបស់ខៀវ សំផន (E289/1)" ១៤ មិថុនា ២០១៣ កថាខណ្ឌ ២៦។

[7] សូមមើល **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា ជូនអង្គជំនុំជម្រះតុលាការកំពូល ឲ្យស៊ើបអង្កេតបន្ថែមទៅនឹងខ្សែវីដេអូរបស់ផលិតករ Rob Lemkin និង ថេត សម្បត្តិ" ៣១ កក្កដា ២០១៥។

[8] **F2/2** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើទីមួយ និង ទីពីររបស់មេធាវីការពារក្តី នួន ជា សុំឲ្យទទួលយក និងពិចារណាទៅលើភស្តុតាងបន្ថែម ទាក់ទងនឹងបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១" ១៦ កញ្ញា ២០១៤ កថាខណ្ឌ ១០។

[9] **F2/4/3/3/4** "សារណាឆ្លើយតបរបស់ នួន ជា" កថាខណ្ឌ ១៤។

ចារិករបស់ Robert Lemkin ។ តែសហព្រះរាជអាជ្ញាអះអាងថា "ប្រតិចារិកបានបង្ហាញមកថាមិនអាចពឹងពាក់បាន"[10] ហើយថែមទាំងបានរិះគន់ដល់តម្លៃ និង ការមិនពេញចិត្តទៅនឹងវិជ្ជាជីវៈរបស់ Robert Lemkin ដោយជំទាស់ទៅនឹងភាពស្មោះត្រង់លើចំណេះដឹង និងសុចរិតភាពរបស់គាត់។ មេធាវីការពារក្តីសូមបញ្ជាក់ថា ចំណុចដែលបានរៀបរាប់ដោយសហព្រះរាជអាជ្ញាថាជា "កត្តា" បន្ថយតម្លៃជាភស្តុតាងរបស់ប្រតិចារិក។

5. **អត្តសញ្ញាណរបស់អ្នកផ្តល់បទសម្ភាសន៍៖** ជាដំបូង សហព្រះរាជអាជ្ញាលើកឡើងថា អត្តសញ្ញាណបុគ្គលទាំងបួន ព្រមទាំងប្រវត្តិ និង មុខងារនៅក្នុងអំឡុងពេលដែលពាក់ព័ន្ធ គឺនៅមិនទាន់ច្បាស់។ តែទោះជាយ៉ាងណាក៏ដោយ ដូចដែលបានបញ្ជាក់ដោយ Robert Lemkin ថា W2 គឺជាអត្តសញ្ញាណច្បាស់ថាជា [redacted] (2-TCW-829)[11]។ បុគ្គលយោងថាជា W1 និង W3 នៅក្នុងប្រតិចារិករបស់ Lemkin ដូចដែលបានពន្យល់ដោយមេធាវីការពារក្តី[12] និងបញ្ជាក់ដោយអង្គជំនុំជម្រះតុលាការកំពូល[13] គឺទំនងជាសាក្សីដែលត្រូវបានស្នើសុំដោយមេធាវីការពារក្តី គឺ [redacted] (2-TCW-961) និង [redacted] (2-TCW-959) ។

6. មេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា សហព្រះរាជអាជ្ញាអនុវត្តយ៉ាងច្បាស់នូវបទដ្ឋានពីរនៅទីនេះ។ តាមពិតមេធាវីការពារក្តីបានលើកឡើងអំពីបញ្ហាអត្តសញ្ញាណនៃប្រភពរបស់ Alexander Hinton នៅក្នុងអំឡុងពេលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង[14] និងបានដាក់សំណើសុំឲ្យស៊ើបអង្កេតបន្ថែមដើម្បីឲ្យភាគី បានទទួលនូវភស្តុតាងក្នុងការត្រួតពិនិត្យភាពជឿជាក់នៃប្រភពភស្តុ

---

[10] **E416/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី" កថាខណ្ឌ ៤ (ង)។

[11] **F2/4/3/3/5** "សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបីស្តីពីកិច្ចស៊ើបសួរបន្ថែម" ២០ សីហា ២០១៥ ជើងទំព័រ ១៥។

[12] **E416** "សំណើសុំភស្តុតាង Lemkin" EN 01298440 កថាខណ្ឌ ១៣។

[13] **F2/4/3/3/5** "សេចក្តីសម្រេចបណ្តោះអាសន្នលើកទីបីស្តីពីកិច្ចស៊ើបសួរបន្ថែម" ERN 01132013 "វាទំនងណាស់ថា បុគ្គលពីររូបនៅក្នុងកំណត់ត្រា និង ឈ្មោះ នៅក្នុងសៀវភៅ *នៅពីក្រោយវាលពិឃាត* គឺនៅក្នុងចំណោមបុគ្គលដែលសក្ខីកម្មរបស់គេត្រូវបានស្នើសុំដោយ នួន ជា នៅក្នុងដំណើរការនីតិវិធីសំណុំរឿង ០០២/០១"។

[14] ប្រតិចារិកសវនាការ ១៥ មីនា ២០១៦ (Alexander Hinton, E1/402.1) ទំព័រ ១៩ [09.38.26] (...) ខ្ញុំគិតថា វាគួរតែច្បាស់សម្រាប់ភាគីថាតើ ទាប គែជាបុគ្គលដែលយើងគិតថា គាត់គឺជា ទាប។ បើមិនដូចនោះទេ យើងកំពុងតែនិយាយពីភស្តុតាងដែលយើងមិនអាចផ្ទៀងផ្ទាត់ [09.39.38] លោក SMITH ខ្ញុំសូមលើកឡើងថា ប្រសិនបើមេធាវីគាត់ចង់សួរថា តើ ទាប ដែលទាក់ទងទៅនឹងបទសម្ភាសន៍នោះ គឺគាត់គួរធ្វើនៅពេលខ្លួនសួរ" ទំព័រ ២៣ [09.45.08] លោក SMITH ទាំងនេះគឺជាសំណួរដែលពាក់ព័ន្ធ ប៉ុន្តែមេធាវីការពារក្តីអាចសួរក្នុងពេលសួរដេញដោលរបស់ខ្លួន។

តាងរបស់គាត់[15]។ តែគួរឲ្យចម្លែកសហព្រះរាជអាជ្ញាបានបដិសេធនូវសំណើរបស់មេធាវីការពារក្តីដោយអះអាងថា៖

> សន្និទានភាពនៃសំណើសុំ មានន័យថា គ្រប់អ្នកជំនាញទាំងអស់ដែលបានកោះហៅមកចំពោះមុខអង្គជំនុំជម្រះអាចនឹងតម្រូវឲ្យផ្តល់គ្រប់ចំណុចនៃប្រភពចំបងនៃសម្ភារៈស្រាវជ្រាវទាំងអស់ដែលគាំទ្រចំពោះមតិយោបល់ជំនាញរបស់ពួកគាត់។ ការណ៍នេះច្បាស់ណាស់ថា នឹងធ្វើឲ្យខូចដល់គោលបំណងនៃការកោះហៅអ្នកជំនាញផង និង ធ្វើឲ្យមានការពន្យារពេលហួសហេតុដល់កិច្ចដំណើរការនីតិវិធីផង[16]។

7. **ការសន្យាដែលត្រូវបានចោទប្រកាន់ និង ការជំរុញដល់អ្នកផ្តល់សម្ភាសន៍:** សហព្រះរាជអាជ្ញាបានលើកឡើងដោយឥតអៀនខ្មាស់ថា "គ្មានការបញ្ជាក់អំពីការសន្យាអ្វីមួយដល់អ្នកផ្តល់បទសម្ភាសន៍ ឬការលើកទឹកចិត្តដល់អ្នកផ្តល់បទសម្ភាសន៍ឲ្យចូលរួមទេ"[17]។ នេះជារឿងមួយនៃការចោទប្រកាន់ដ៏អាក្រក់បំផុតរបស់សហព្រះរាជអាជ្ញាក្នុងការជំទាស់ទៅនឹងភាពស្មោះត្រង់ខាងចំណេះដឹងរបស់ Robert Lemkin។ នៅក្នុងករណីណាក៏ដោយវាចម្លែកក្នុងការលើកឡើងចំពោះការបារម្ភទាំងនេះ ហើយសហព្រះរាជអាជ្ញាមិនគិតទៅដល់បុគ្គលរាប់ពាន់នាក់ដែលភស្តុតាងរបស់គាត់ត្រូវបានទទួលយកនៅក្នុងសំណុំរឿងនេះ។ ជាពិសេសសហព្រះរាជអាជ្ញាមិនដែលសួរអំពី"ការជំរុញ" ទៅលើជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ដែលត្រូវបានសួរដោយ Ysa Osman ហើយក៏មិនបានសួរ Alexander Hinton អំពី "ការសន្យា" ដែលគាត់អាចមានក្នុងពេលសម្ភាសជាមួយបុគ្គលទាំងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ទាំង Ysa Osman និង Alexander Hinton បានផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០២/០២ តែមេធាវីការពារក្តីគ្រាន់តែស្នើសុំ Robert Lemkin ជាសាក្សីធម្មតាតែប៉ុណ្ណោះ។

8. **ការរិះគន់ទៅលើវិធីសាស្ត្រ:** សហព្រះរាជអាជ្ញាបានបន្ថែមការិះគន់ជាច្រើនទៅលើវិធីសាស្ត្ររបស់ Lemkin[18]។ គួរឲ្យភ្ញាក់ផ្អើលជាថ្មីម្តងទៀតសហព្រះរាជអាជ្ញាមិនដែលទាមទាបទដ្ឋានដូចគ្នាចំពោះបុគ្គលដែលនឹងមកផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញ។ បន្ថែមពីលើនេះ វាគួរឲ្យចាប់អារម្មណ៍ក្នុងការកត់សម្គាល់ថា វិធីសាស្ត្រដែលរៀបរាប់ដោយ Robert Lemkin ក្នុងការសម្ភាសសាក្សីបួនរូប គឺដូចគ្នាណាស់ទៅនឹងវិធីសាស្ត្រ ដែលអនុវត្តដោយសហព្រះរាជអាជ្ញាចំពោះសាក្សីរបស់ខ្លួន Alexander

---

[15] **E405** "សំណើសុំឲ្យស៊ើបសួររបស់ នួន ជា ទាក់ទិននឹង Alexander Laban Hinton" ០៩ ឧសភា ២០១៦ កថាខណ្ឌ ១១ ដល់ ១៣។

[16] **E405/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទិននឹង Alexander Hinton (2-TCE-88)" ១៩ ឧសភា ២០១៦ កថាខណ្ឌ ៨។

[17] **E416/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី" កថាខណ្ឌ ៤ (គ)។

[18] **E416/1** "ចម្លើយតបរបស់សហព្រះរាជអាជ្ញា និង សំណើថ្មី" កថាខណ្ឌ ៤ (ឃ) (ង) (ឆ) (ជ) (ឈ)។

Hinton ។ តាមពិតទៅ Robert Lemkin បានពន្យល់ថា "បុគ្គលដែលត្រូវបានសម្ភាសជាច្រើនដង (...) ការប៉ុនប៉ងត្រូវបានធ្វើឡើងដើម្បីផ្ទៀតផ្ទាត់ ឬក៏បន្ថែមទៅនឹងពត៌មានដោយការសួរបុគ្គលផ្សេងទៀតអំពីពត៌មានដែលបុគ្គលម្នាក់បានផ្តល់"[19] ចំណែកឯ Alexander Hinton បាននិយាយថា គាត់ "បានព្យាយាមធ្វើការផ្ទៀងផ្ទាត់ ក្នុងន័យថា ប្រសិនបើអ្នកណាម្នាក់និយាយអ្វីមួយ ខ្ញុំព្យាយាមផ្ទៀតផ្ទាត់ជាមួយបុគ្គលផ្សេងទៀត ដែលអាចបញ្ជាក់អំពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ"[20]។

9. ដូចដែលបានលើកឡើងរួចហើយនៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល ក្រុមមេធាវីការពារក្តីយល់ឃើញថា សម្ភារះរបស់ Robert Lemkin គឺអាចទុកចិត្តបានច្រើនជាងការសម្ភាសន៍ដែលធ្វើឡើងដោយ François Ponchaud, Philip Short ឬ Steve Heder ហើយដែលត្រូវបានពឹងផ្អែកយ៉ាងជាប់លាប់នៅទូទាំងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១ ជាភស្តុតាងដ៏សំខាន់នៅក្នុងការគាំទ្របញ្ហានៃអង្គហេតុដែលរងការជំទាស់ដ៏ខ្លាំងខ្លានេះ[21]។ ម្យ៉ាងវិញទៀតក្រុមមេធាវីការពារក្តីមិនស្វែងរកឲ្យទទួលយកជាភស្តុតាងនូវមតិយោបល់របស់ Lemkin ឬ កោះហៅ Lemkin ជាសាក្សីជំនាញឡើយ។ ក្រុមមេធាវីការពារក្តីគ្រាន់តែស្វែងរកឲ្យទទួលយកជាភស្តុតាងនូវប្រភពដើម និងសក្ខីកម្មដើមនៃការសម្ភាសន៍ដែលគាត់បានផ្តួចផ្តើម បានធ្វើផែនការ បានចូលរួម និងបានពិនិត្យឡើងវិញយ៉ាងដិតដល់ប៉ុណ្ណោះ ។

10. ជាចុងក្រោយក្រុមមេធាវីការពារក្តីសង្កត់ធ្ងន់ថា ក្រុមមេធាវីការពារក្តីបានប្រឹងប្រែងយ៉ាងច្រើន ដើម្បីឲ្យ Robert Lemkin ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យលទ្ធភាព ឲ្យភាគីដាក់សំណួរចំពោះគាត់ ទាក់ទងនឹងបញ្ហាវិធីសាស្ត្រទាំងនេះ[22]។

11. ប្រតិចារិក គឺជាភស្តុតាងដែលបានមកពីទារុណកម្មៈ ក្រុមមេធាវីការពារក្តីយល់ឃើញម្តងទៀតថា វាសមហេតុផលទាំងស្រុងសម្រាប់ Lemkin និង ថេត សម្បត្តិ បង្ហាញអ្នកធ្វើសម្ភាសន៍នូវចម្លើយសារភាព

---

[19] **F2/4/3/1** "កំណត់ហេតុស្តាប់ចម្លើយ Lemkin" ចម្លើយទី ២០។

[20] ប្រតិចារិកសវនាការ ១៥ មីនា ២០១៦ (Alexander Hinton, E1/402.1) ទំព័រ ១២៣ ដល់ ១២៤។

[21] សូមមើលផងដែរ F2/4/3/3/4 "ចម្លើយតបទៅនឹងសហព្រះរាជអាជ្ញាទាក់ទងនឹងកំណត់ហេតុរបស់ Lemkin ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០១៥ នៅកថាខណ្ឌ១៧ ។

[22] នៅក្នុងសំណុំរឿង០០២/០២ ឧទាហរណ៍ឯកសារ E335/1 "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំកោះហៅងថេត សម្បត្តិ ជាសាក្សីអាទិភាព ថ្ងៃទី២៦ ខែមករា ឆ្នាំ ២០១៥ ។ ឯកសារ E335/1/1 "សារណាឆ្លើយតបរបស់ នួន ជា ទៅនឹងសំណួររបស់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងសំណើអនុលោមតាមវិធាន ៨៧(៤) របស់ក្រុមមេធាវីការពារក្តី សុំកោះហៅ Robert Lemkin ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០១៥ ។ ឯកសារ E395 សំណើលើកទី៣ របស់ នួន ជា សុំកោះហៅសាក្សី សម្រាប់មន្ទីរសន្តិសុខនៅក្នុងសំណុំរឿង០០២ និង "ការបោសសំអាត "ផ្ទៃក្នុង" ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៦។

របស់ រស់ ញឹម ដើម្បីចំរាញ់យកមតិយោបល់របស់ពួកគេទាក់ទងនឹង ថាតើវាឆ្លុះបញ្ចាំងពេញលេញពីសមត្ថភាពក្បត់របស់ រស់ ញឹម ដែរ ឬយ៉ាងណានោះ ។ ម្យ៉ាងវិញទៀតសហព្រះរាជអាជ្ញាមិនដែលរអ៊ូរទាំអំពីការទទួលយកជាភស្តុតាងនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយបុគ្គលនានាដែលត្រូវបានបង្ហាញនូវចម្លើយសារភាព នៅមុនពួកគេត្រូវបានស្តាប់ចម្លើយដោយសហចៅក្រមស៊ើបអង្កេត[23] ហើយពួកគេក៏មិនបានជំទាស់ការទទួលយកជាភស្តុតាងនៃសៀវភៅជាច្រើន ដែលពឹងផ្អែកយ៉ាងខ្លាំងលើខ្លឹមសារនៃចម្លើយសារភាព[24]។

12. មិនដូចសហព្រះរាជអាជ្ញាបានធ្វើនោះទេនៅពេលពួកគេបានជំទាស់ទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តីសុំផ្តល់ប្រភពរបស់ Alexander Hinton[25] ក្រុមមេធាវីការពារក្តីតែងតែបានស្វែងរកឲ្យមានតម្លាភាពនៅក្នុងការស្នើសុំកោះហៅ Robert Lemkin និង សាក្សីបីរូបដែលត្រូវបានកំណត់ អត្តសញ្ញាណនៅក្នុងសៀវភៅរបស់ ថេត សម្បត្តិ ឲ្យផ្តល់សក្ខីកម្ម និងការស្វែងរកឲ្យសម្ភារៈរបស់ Lemkin ត្រូវបានទទួលយកជាភស្តុតាង។ ជាថ្មីម្តងទៀតក្រុមមេធាវីការពារក្តីខកចិត្តដោយបទដ្ឋានដែលអនុវត្តទៅលើភាគីម្ខាង តែមិនអនុវត្តចំពោះសហព្រះរាជអាជ្ញា (double standard) ដោយសារវាមិនបានបំរើអ្វីទាំងអស់ ក្រៅពីតែការពិភាក្សារវាងភាគី ជាជាងការរួមចំណែកដើម្បីជួយបញ្ជាក់ការពិតឡើយ។

## *(ii) កំណត់ត្រា*

13. ស្រដៀងគ្នានេះដែរសហព្រះរាជអាជ្ញាមិនប្រឆាំងការទទួលយកជាភស្តុតាងនៃកំណត់ត្រារបស់ Lemkin តែតវ៉ាយ៉ាងម៉ឺងម៉ាត់ពីភាពអាចទុកចិត្តរបស់វា ដោយបានចង្អុលបង្ហាញពីកំហុសនៅក្នុងវិធីសាស្ត្ររបស់ Lemkin។ ក្រុមមេធាវីការពារក្តីសូមឲ្យអង្គជំនុំជម្រះចាប់អារម្មណ៍ផ្តែកខាងលើទាក់ទងនឹងបញ្ហាវិធីសាស្ត្រ និង គូសបញ្ជាក់ឡើងវិញថា សហព្រះរាជអាជ្ញានឹងមានឱកាសដោះស្រាយបញ្ហានេះនៅពេលពួកគេសួរដេញដោល Robert Lemkin ប្រសិនបើអង្គជំនុំជម្រះកំណត់កាលបរិច្ឆេទឲ្យគាត់បង្ហាញខ្លួនផ្តល់សក្ខីកម្ម។

---

[23] E3/80, កំណត់ហេតុជាលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី មាស វឿន ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១០ ERN 00491657

[24] សូមមើលឧទាហរណ៍ឯកសារ E3/2653 ការបះបោររបស់ជនជាតិចាម (The Cham Rebellion) ដោយ Ysa Osman ។ ឯកសារ E3/1664, សំឡេងពីស២១ Voices from S-21 ដោយ David Chandler

[25] E405/1 "សារណាឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ នួន ជា សុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹង Alexander Hinton'

*(iii)* ***អត្ថបទ***

14. ក្រុមមេធាវីការពារក្តីកត់សម្គាល់ថា សំណៅនៃអត្ថបទដែលត្រូវបានដាក់ភ្ជាប់ជាមួយសំណើរបស់ខ្លួន ហើយដែលជាឯកសារស្តែនពីសំណៅដើមនៃសារព័ត៌មាន លុបផ្នែកនៃប្រយោគមួយ។ ដូច្នេះ ក្រុមមេធាវីការពារក្តីសូមភ្ជាប់សំណៅអេឡិចត្រូនិកនៃអត្ថបទ[26]។

**ខ. សារណាឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំបំពេញកិច្ចស៊ើបសួរ**

15. សហព្រះរាជអាជ្ញាបានបន្ថែមសំណើសុំកិច្ចស៊ើបសួរថ្មីមួយទៅលើសារណាឆ្លើយតបរបស់ពួកគេ និងអនុលោមតាមវិធាន ៩៣ បានស្នើអង្គជំនុំជម្រះសាលាដំបូងឱ្យស្វែងរកប្រមូលពី Robert Lemkin នូវ "footage និង/ឬប្រតិចារិតបន្ថែមនៃការសម្ភាសន៍ នួន ជា ខៀវ សំផន និងសាក្សីដ៏ទៃទៀតដែលមានយោងនៅក្នុងប្រតិចារិក ឬ កំណត់ត្រា" ។ ក្រុមមេធាវីការពារក្តីមិនជំទាស់ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាទេ តែបញ្ជាក់ជាថ្មីម្តងទៀតនូវភាពពិសេសរបស់វា ដោយការពិចារណាការកង្វះនូវការគោរពរបស់សហព្រះរាជអាជ្ញាជាយូរណាស់មកហើយចំពោះស្នាដៃរបស់ Robert Lemkin។

សហមេធាវីការពារក្តី នួន ជា

សុន អរុណ Victor KOPPE

[26] Cambodia Daily Weekend', 18-19 Jun 2016, https://www.cambodiadaily.com/weekend1/factions-or-fiction-114272/ និងជាភាសាខ្មែរ: http://www.cambodiadailykhmer.com/32489 **(ឯកសារភ្ជាប់ ២)**។